**SLIDE #1**

- នៅឆ្នាំ 2007 កំណើនប្រាក់បញ្ញើកើនលើសកំណើនទ្រព្យសម្បត្តិ។
- កំណើនជាទូទៅនៅក្នុងវិស័យធនាគារផ្លូវការ (ស្របច្បាប់) បានបន្តកើនឡើងខ្លាំង ក្នុងឆ្នាំ 2007 ដោយមានអត្រាកំណើនដូចខាងក្រោម :
    - កំណើនប្រាក់បញ្ញើ 72% yoy
    - កំណើនប្រាក់កម្ចី 64% yoy
- តាមការព្យាករណ៍កំណើនទីផ្សារក្នុងឆ្នាំ 2008 យើងនៅតែរក្សាបានកំណើនវិជ្ជមាន ដែលតាមការប៉ាន់ស្មានកំណើនប្រាក់បញ្ញើមាន 40-50% និងកំណើនទ្រព្យសម្បត្តិមាន 50-60% ។
- ការប្រកួតប្រជែងទីផ្សារបានកើនឡើងខ្លាំងនៅឆ្នាំ 2007 ហើយយើងរំពឹងទុកថា ទីផ្សារនៅតែមានការប្រកួតប្រជែងបន្តទៀតនៅក្នុងឆ្នាំ 2008 ។
- ការវិភាគអំពីរូបិយប័ណ្ណក្នុងវិស័យ (ធនាគារ) ផ្លូវការ និងក្រៅផ្លូវការនៅតែ មានអត្រាអតុល្យភាព :
    - មានប្រាក់បញ្ញើនៅធនាគារតែ 3% ប៉ុណ្ណោះជារូបិយប័ណ្ណប្រាក់រៀល (ប្រហែល 161 កោដិរៀល ឬ 39 លានដុល្លារអាមេរិក)។

**SLIDE #2**

- កត្តាហានិភ័យមានកម្រិតខ្ពស់ តែផ្តល់ការតបស្នងទាប។
- ការមិនមានតម្លាភាព និងការបញ្ជាក់ស្តង់ដារគឺជាឧបសគ្គដល់ការវាយតម្លៃអំពី សក្តានុពលនៃកាលានុវត្តភាព។
- ច្បាប់ពាណិជ្ជកម្ម និងក្ស័យធនថ្មីៗនេះមិនទាន់មានការពិនិត្យស្រាវជ្រាវទ្រព្យសម្បត្តិ ដែលជាឯកសារយោងជួយឱ្យធនាគារមានលទ្ធភាពបង្គំទារសំណង។
- ការកំណត់ថ្លៃចំពោះហានិភ័យទាំងនេះមិនស្របតាមអត្រាផលធៀបប្រាក់ចំណេញ និងទ្រព្យសម្បត្តិ (ROA) និងអត្រាផលធៀបប្រាក់ចំណេញ និងទ្រព្យម្ចាស់ហ៊ុន (ROE) នៅតាមបណ្តាប្រទេសអភិវឌ្ឍ។

**SLIDE #3**

ការមិនមានរបាយការណ៍ហិរញ្ញវត្ថុ និងទិន្នន័យដែលអាចទុកចិត្តបានគ្រប់គ្រាន់គឺជាឧបសគ្គចំពោះកំណើននៃការទទួលឥណទាន។

*កាលានុវត្តភាព :*

*ធនាគារកំពុងលើកទឹកចិត្តដល់អតិថិជនក្នុងការរៀបចំ និងការរក្សាទុករបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ ហើយការងារនេះត្រូវបានធ្វើឱ្យប្រសើរឡើងតាមរយៈការកំណត់ និងតម្រូវការក្នុងការប្រមូលពន្ធ។*

ការចំណាយខ្ពស់ដើម្បីទទួលបានលិខិតបញ្ជាក់កម្មសិទ្ធិដីធ្លីស្របច្បាប់ និងការប្រើប្រាស់ដីធ្លីជាទ្រព្យធានាមានតិចតួចដែលអាចធ្វើឱ្យធនាគារជឿទុកចិត្តក្នុងការផ្តល់ប្រាក់កម្ចីបានក្លាយជាឧបសគ្គដល់ដំណើរការទទួលបានឥណទាន។

កាលានុវត្តភាព

*ការផ្តល់ធនធានបន្ថែមដល់គំនិតផ្តួចផ្តើម ឡ្វាំផ អាចជួយឱ្យអាជីវកម្មនានាទទួលបាន ហិរញ្ញវត្ថុ (ឥណទាន) ដែលមានថ្លៃដើមទាប។*

លទ្ធភាពក្នុងការបង្ខំឱ្យអនុវត្តកិច្ចសន្យាដោយផ្អែកតាមច្បាប់ថ្មីដែលបានអនុម័តនាពេលកន្លងទៅនេះនៅមិនទាន់មានភាពច្បាស់លាស់។

*កាលានុវត្តភាព :*

*បន្តពង្រឹងប្រព័ន្ធតុលាការ ដំណើរការកាត់ក្តី និងតុលាការពាណិជ្ជកម្មដើម្បីផ្តល់ភាពជឿជាក់ដល់ប្រតិបត្តិករហិរញ្ញវត្ថុនៅក្នុងប្រតិបត្តិការពាណិជ្ជកម្ម។*